គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៣៧ ចេញផ្សាយថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២
No. 37 Released on March 14, 2022

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# អត្តសញ្ញាណរបស់អត្ថគាហកៈ

## Identity of the Beneficiary



រូបភាព | Picture: https://www.flaticon.com/free-icon/beneficiary_5774997

យោងតាមមាត្រា ២៦ នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) អត្ថគាហកៈអាចជាបុគ្គលដែលត្រូវបានបង្កើតស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ឬអាចជាបរធនបាលទាយក។ អត្ថគាហកៈ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលផលប្រយោជន៍ពីបរធនបាលកិច្ច។

ប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ក្នុងប្រការ ៦ បានចែងថាបរធន-បាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ដោយមានជំនួយពីបរធនបាល ត្រូវកំណត់ជាក់លាក់នូវអត្ថគាហកៈនៅក្នុងលិខិតបរធនបាលកិច្ច ហើយត្រូវផ្តល់ឱ្យនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) នូវព័ត៌មាន និងការកំណត់អត្តសញ្ញាណរបស់អត្ថគាហកៈ ដោយត្រូវមានលក្ខណៈពិតប្រាកដ ច្បាស់លាស់ មិនក្លែងបន្លំ ព្រមទាំងមិនពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

According to the Article 26 of the Law on Trust (2019) a beneficiary may be the person legally established in the Kingdom of Cambodia or may be a trustor. Beneficiary refers to the physical person or legal entity who might benefit from the trust.

Article 6 of the Prakas on the Rules for the Management, Organization and Functioning of the Trust states that the trustor or contributor of the trust that assisted by a trustee has to define specifically the beneficiary in the trust instrument and provides the Trust Regulator (TR) with certain, accurate, correct as well as non-fraudulent and not involved in money laundering, terrorist financing of proliferation of weapons of mass destruction.

**អត្ថបទ÷ កេត ស្រីនិច | Article: Ket Sreynich**

**ឯកសារយោង | References:**

- មាត្រា ២៦ នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- ប្រការ ៦ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.